# ការយល់ដឹងអំពីកម្មវិធីវិទ្យុសហគមន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា
## អៀង ណារី

នាងខ្ញុំឈ្មោះ អៀង ណារី ជានិស្សិតឆ្នាំទី៣ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ផ្នែកប្រវត្តិ-សាស្រ្ត ។ នាងខ្ញុំមានស្រុកកំណើតនៅភូមិពាមកោះ ឃុំពាមរក៍ ស្រុកពាមរក៍ខេត្តព្រៃវែង ។

បន្ទាប់ពីនាងខ្ញុំបានស្តាប់កម្មវិធីវិទ្យុសហគមន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលផ្សាយអំពីអំពើប្រល័យពូជសាសន៍នៅក្នុងរបបខ្មែរក្រហមរួចមក នាងខ្ញុំមានចំណាប់អារម្មណ៍យ៉ាងខ្លាំងចំពោះកម្មវិធីនេះ ។ ក្នុងនាមនាងខ្ញុំជានិស្សិតមួយរូបដែលសិក្សាផ្នែកប្រវត្តិសាស្រ្ត នាងខ្ញុំពិតជាមានសេចក្តីត្រេកអរជាខ្លាំង ដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានយកចិត្តទុកដាក់ក្នុងការផ្សព្វផ្សាយជាសាធារណៈនូវអំពើប្រល័យពូជសាសន៍ដ៏យង់ឃ្នងមួយនេះ ។ ក្នុងការស្តាប់វិទ្យុសហគមន៍នេះ ខ្ញុំទទួលបានចំណេះដឹងនិងការយល់ដឹងច្រើនអំពីបញ្ហានៃអំពើប្រល័យពូជសាសន៍ដែលបានកើតមាននៅក្នុងប្រទេសកម្ពុជា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ១៩៧៥-១៩៧៩ ។ ក្នុងនោះផងដែរ ការអនុវត្តនៅក្នុងរបបនោះបានធ្វើឲ្យប្រជាពលរដ្ឋខ្មែរមានការឈឺចាប់យ៉ាងខ្លាំង ។ ព្រោះសម័យនោះ ខ្មែរក្រហមបានធ្វើទុក្ខបុកម្នេញយ៉ាងធ្ងន់ធ្ងរទៅលើប្រជាជនខ្មែរ ។ ការធ្វើបាបទាំងនោះរួមមាន ការធ្វើទារុណកម្ម ការផ្តល់របបអាហារមិនគ្រប់គ្រាន់ ការធ្វើបាបប្រជាជនថ្មី និងការកាប់សម្លាប់គ្មានត្រាប្រណីចំពោះជនសង្ស័យគ្រង់ ។ នេះហើយជាបញ្ហាដែលចោទក្នុងការធ្វើឲ្យមានភាពអត់ឃ្លានកើតឡើងនៅកម្ពុជាក្នុងសម័យខ្មែរក្រហម ។ ខ្ញុំក៏បានដឹងខ្លះៗ អំពីដំណើរការនៃការកាត់ក្តីរបស់តុលាការខ្មែរក្រហម ដែលបានលើកមកនិយាយនៅក្នុងកម្មវិធីនេះផងដែរ ។ លើសពីនេះទៅទៀត នាងខ្ញុំក៏បានស្គាល់នូវអ្វីដែលហៅថាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនិងឧក្រិដ្ឋកម្មអន្តរជាតិផ្សេងៗ ដែលបានកើតឡើងនៅបណ្តាប្រទេសនានា ។ ទាំងអស់នេះជាអ្វី ដែលធ្វើឲ្យនាងខ្ញុំមានការចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះកម្មវិធីនេះ ។

ចុងបញ្ចប់ ក្នុងនាមនាងខ្ញុំជាកូនខ្មែរមួយរូប នាងខ្ញុំពិតជាមានការសោកស្តាយយ៉ាងខ្លាំង ដែលប្រទេសកម្ពុជាយើងបានកើតមាននូវរបបនេះ ។ ទោះជាយ៉ាងណាក៏ដោយ របបនេះមិនមែនកើតឡើងតែនៅក្នុងប្រទេសកម្ពុជាយើងនោះទេ តែវាបានកើតឡើងនៅបណ្តាប្រទេសខ្លះរួចមកហើយ ។ ដូចនេះ

យើងអាចធ្វើការប្រៀបធៀបរវាងប្រទេសខ្មែរ និងប្រទេសដទៃទៀតបាន។ ការកើតមានភាពអត់ឃ្លាន នៅមិនទាន់ដោះស្រាយបាននៅឡើយទេនៅក្នុងប្រទេសមួយចំនួន ដូចជា ប្រទេសសូមាលី ជាដើម។ ដូចនេះ នាងខ្ញុំជានិស្សិតមួយរូប នាងខ្ញុំនឹងខិតខំធ្វើការផ្សព្វផ្សាយទៅកាន់ប្រជាជនមួយចំនួន ដែលមិនបាន យល់ដឹងអំពីរឿងរ៉ាវទាំងអស់នេះ។ នាងខ្ញុំនឹងរក្សារឿងរ៉ាវទាំងអស់នេះ ទុកជាបទពិសោធន៍ សម្រាប់ មនុស្សជំនាន់ក្រោយ ដើម្បីចេះធ្វើការថ្លឹងថ្លែង និងប្រៀបធៀបនូវអ្វីដែលបានកើតឡើងនៅក្នុងរបប ខ្មែរក្រហម និងធ្វើយ៉ាងម៉េចដើម្បីកុំឲ្យរបបនេះកើតមានជាលើកទីពីរនៅក្នុងប្រទេសកម្ពុជាយើងនេះ។

-ចប់-

# My Personal Reflection on DC-Cam's Community Radio Program[1]

My name is Ieng Nary, and I am a third-year student at the Royal University of Phnom Penh, majoring in History. I was born in Prey Veng Province.

After I listened to DC-Cam's Community Radio Program on the Khmer Rouge genocide, I became very interested in this program. As a history student, I am very grateful to DC-Cam for their determination in broadcasting the facts about this cruel regime to the public. By listening to this radio program, I have gained a variety of knowledge on the history of genocide in Cambodia from 1975 to 1979. Moreover, I have developed a better understanding about the ways in which the policies of the Khmer Rouge seriously harmed Cambodians. Those policies included torture, starvation, abuse of urban (new) people, and execution of innocent people. In addition to Khmer Rouge history, this program informed me about the progress of the Khmer Rouge Tribunal. Furthermore, I was able to learn about the definitions of crimes against humanity and other international crimes which have occurred around the world.

Finally, as a Cambodian, I truly regret that this regime held power in my country. However, Cambodia is not the only country to have suffered from such a regime. As a university student, I will share what I have learned from this program with those who have less understanding of the Khmer Rouge regime. At the same time, I would like to share these stories with other members of the young generation so as to remember this tragic past and prevent it from happening in the future.

[1] Translated by Lorn Dalin; edited by Elaine McKinnon.